# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត

XINLAN (CAMBODIA) GARMENT COMPANY LIMITED

អាសយដ្ឋាន ភូមិ ព្រៃបឹង សង្កាត់ កន្ទោក ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

## <u>កំណត់ហេតុ</u>

## <u>ស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារនិងនិតិវិធីក្នុងការបើកប្រាក់ឈ្នួល</u>

-យោងតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរក្សាលំនឹងជីវភាពរបស់បងប្អូនកម្មករនិយោជិត និងធានានូវស្ថេរភាពអាជីវកម្មរបស់រោងចក្រដែលជួបការលំបាកខ្វះបញ្ជាទិញ និងជួបវិបត្តិនៃការផលិតក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចសកល ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រត្រូវធ្វើការពិភាក្សាគ្នាជាមួយតំណាងបងប្អូនកម្មករនិយោជិតដើម្បីកំណត់ការផ្លាស់វេនគ្នាធ្វើការងារនៅពេលមានការព្យួរកិច្ចសន្យាការងារក្នុងរយៈពេលកំណត់ណាមួយដោយផ្អែកលើគោលការណ៍សមភាព។

-យោងសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០២០/២៣ កប/ស ណ ន ខ ល ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូបដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល។

នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣ វេលាម៉ោង ០៩: ០០ នាទី មានការបើកអង្គប្រជុំមួយក្រោមអធិបតីលោក YIN JULIANG ជានាយកក្រុមហ៊ុន និង លោក កង វ៉ាន់ណែត ជាលេខាកត់ត្រាបានបើកអង្គប្រជុំមួយស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារនិងនិតិវិធីក្នុងការបើកប្រាក់ឈ្នួលដែលមានទីតាំងនៅក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត។

**សមាសភាពចូលរួមជាភ្ញៀវកិត្តិយសរួមមាន :**

-លោក YIN JULIANG តួនាទីជានាយកក្រុមហ៊ុន

Scanned with CamScanner

-លោក គង វ៉ាន់ណែត តួនាទី ប្រធានរដ្ឋបាល

-ប្រធានក្រុម និងប្រធានផ្នែក

- តំណាងប្រតិភូបុគ្គលិកពេញសិទ្ធទាំងអស់

ជាកិច្ចចាប់ផ្តើមលោក YIN JULIANG ជាប្រធានអង្គប្រជុំបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ប្រធានក្រុម ប្រធានផ្នែក ព្រមទាំងកម្មករនិយោជិតទាំងអស់ដែលបានចូលរួមក្នុងការសហការនេះ។ ក្នុងនាមលោក ជាប្រធានអង្គប្រជុំក៏បានបញ្ជាក់ផងដែរនូវគោលបំណងនៃកិច្ចប្រជុំ ដោយលោកនាយកបានបញ្ជាក់ថា ដោយសាគ្មានការបញ្ជាទិញពីអតិថិជននៅសហរដ្ឋអាមេរិកនិងប្រទេសផ្សេងៗទៀត ម្យ៉ាងទៀតទំនិញដែលបានផលិតរួចរាល់ក៏អតិថិជនមិនទាន់ឲ្យនាំចេញជាហេតុធ្វើឲ្យក្រុមហ៊ុនជួបនូវការលំបាកផ្នែកហិរញ្ញវត្ថុដែលក្រុមហ៊ុនចាំបាច់ត្រូវកាត់ បន្ថយកម្មករនិយោជិតខ្លះ។គិតត្រឹមថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២៣ ក្រុមហ៊ុនស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេភនី លីមីធីត មានកម្មករនិយោជិតចំនួន ៣៤៧ នាក់ ហើយចំនួនកម្មករនិយោជិតដែលនឹងត្រូវដាក់ពាក្យស្នើសុំព្យួរការងារមានចំនួន ៣៨ នាក់ ក្នុងនោះមានកម្មការិនីចំនួន ៣៨ នាក់ រយះពេលនៃការព្យួរ ០២ ខែ ដោយគិតចាប់ពីថ្ងៃទី០១ខែ មិថុនា ដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២៣

-របៀបក្នុងការបើកប្រាក់ឈ្នួល

ក្រោយពីបានធ្វើការណែនាំយ៉ាងច្បាស់លាស់អំពីគោលការណ៍រួចហើយ អង្គប្រជុំបានមូលមតិគ្នាជាឯកឆន្ទ័កំណត់ការបើកប្រាក់ឈ្នួលសរុបទាំងពីរលើកចំនួន ៦០ ដុល្លាអាមេរិកនៅថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០២៣ សម្រាប់ការសុំព្យួរកិច្ចសន្យាការងារ គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា រហូតដល់ថ្ងៃទី ៣១ខែ កក្កដា ឆ្នាំ ២០២៣ ។

កិច្ចពិភាក្សារការងារបានចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសសោមនស្សរីករាយ និងស្និទស្នាលក្រៃលែងជាងទីបំផុត។

ថ្ងៃ អង្គារ ១៣រោច ខែ ពិសាខ ឆ្នាំ ថោះ បញ្ចាស័ក ពស ២៥៦៧

ត្រូវនឹង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣

បានឃើញ និង ឯកភាព

នាយកក្រុមហ៊ុន

KINGDOM OF CAMBODIA

Yin Juliang

លេខាកត់ត្រា

ប្រធានរដ្ឋបាល

Kang Vannet

ហត្ថលេខានិងស្នាមមេដៃប្រតិភូបុគ្គលិកពេញសិទ្ធ

Scanned with CamScanner